២–ក្រុមហ៊ុនចំការកៅស៊ូមេមត់បរិច្ចាគប្រាក់ ៣.០០០ $ សំរាប់ទ្រទ្រង់សមរភូមិមុខ ។

៣–ក្រុមហ៊ុនចំការកៅស៊ូ ជប់ បរិច្ចាគ ២.០០០ $ សំរាប់ទ្រទ្រង់សមរភូមិមុខ ។

៤–ក្រុមហ៊ុនចំការកៅស៊ូ ក្រែក បរិច្ចាគប្រាក់ ២.០០០ $ សំរាប់ទ្រទ្រង់សមរភូមិមុខ ។

៥–ក្រុមហ៊ុនភាពីម៉ិច បរិច្ចាគប្រាក់ ១.២០០ $ សំរាប់ទ្រទ្រង់សមរភូមិមុខ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាល ខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខានិងត្រា
**នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខានិងត្រា
**ហ៊ុន សែន**

* * *

## ២–សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៩៦

### សេចក្តីសំរេចលេខ ២០ សសរ
### ស្តីពីការផ្ទេរសិទ្ធិ

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

– បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល ។

– បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រីដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ។

– តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ។

**សំរេច**

**ប្រការ ១** : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ម៉ុក ម៉ារ៉េត** រដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិស្ថាន ជារដ្ឋលេខាធិការ ស្តីទី នៃក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជនជំនួសឯកឧត្តម **ស៊ុយ សែម** ដែលត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅបរទេស ចាប់ពីថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៩៦ រហូតដល់ ឯកឧត្តមបញ្ចប់បេសកកម្ម ។

**ប្រការ ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តម **ម៉ុក ម៉ារ៉េត** ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខានេះតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្ថលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ១៩៩៦

**សេចក្តីសំរេចលេខ ២១ សសរ**

**ស្តីពីការបង្កើតប្រធានគណៈកម្មការរៀបចំបុណ្យសព**

**មាត្រា ១** : ត្រូវបានបង្កើតប្រធានគណៈកម្មការបុណ្យសពសម្តេចចក្រី **ញឹក ជូឡុង** ឧត្តមទីប្រឹក្សា ព្រះមហាក្សត្រដូចមានរាយនាមខាងក្រោម ÷

១-ឯកឧត្តម **គង់ សំអុល** ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីបរមរាជវាំង ជាប្រធាន

២-ឯកឧត្តម ឧត្តមសេនីយឯក **ឡៅ ឆាញ់** សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាអនុប្រធាន

៣-ឯកឧត្តម ឧត្តមសេនីយឯក **ឌា ចាំង** សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាអនុប្រធាន

៤-ឯកឧត្តម ឧត្តមសេនីយឯក **ឌេត ប៉ែន** ឧត្តមទីប្រឹក្សាព្រះមហាក្សត្រ ជាសមាជិក

៥-ឯកឧត្តម ឧត្តមសេនីយឯក **កែ គឹមយ៉ាន** នាយអគ្គសេនាធិការ ជាសមាជិក